ក្រុមប្រឹក្សាយល់ថា: ជនជាប់ចោទ [redacted] បញ្ញា បានសារភាពអំពីប្រព្រឹត្តរបស់ខ្លួនៗហេតុនេះការសម្រេចផ្តន្ទាទោសរបស់សាលាដំបូង**ពីបទ:លួច** តាមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌមានលក្ខណៈត្រឹមត្រូវ ។

៣/សំអាងហេតុនៅក្នុងសាលក្រមព្រហ្មទណ្ឌលេខ ២៨ "ឋ" ចុះថ្ងៃទី ១៣-៧-២០១២ មានលក្ខណៈត្រឹមត្រូវហើយ សាលាឧទ្ធរណ៍ឯកភាព នឹងសំអាងហេតុនេះ ដោយមិនចាំបាច់លើកមកសំអាងជាថ្មីទេ ។

៤/ការស្នើសុំបន្ធូរបន្ថយទោសរបស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ក្រុមប្រឹក្សាមិនអាចពិចារណាបានទេ ដោយហេតុថាឈ្មោះ [redacted] បញ្ញា បានសារភាពថាខ្លួនបានប្រព្រឹត្តបទល្មើស ប្លន់ ឬ លួចនេះមានបួនសំណុំរឿងៗនេះបង្ហាញថាឈ្មោះ [redacted] បញ្ញា ជាជនដែលមិនចេះកែកំហុស ឬ អត្តចរិតរបស់ខ្លួនឱ្យបានល្អក្នុងការរស់នៅក្នុងសង្គមបានល្អទេ ។

៥/សាលក្រមព្រហ្មទណ្ឌលេខ ២៨ "ឋ" ចុះថ្ងៃទី ១៣-៧-២០១២ បានសម្រេចមកមានលក្ខណៈត្រឹមត្រូវហើយ គប្បីតម្កល់ទុកជាបានការ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១/ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២/តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៨ "ឋ" ចុះថ្ងៃទី ១៣/៧/២០១២ របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការ ។

៣/បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] បញ្ញា តាមនីតិវិធីច្បាប់ ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៣ខែមេសា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទ បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

***សេចក្តីនេះព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួល បន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកម្លាំងប្រដាប់អាវុធជួយសហការអនុវត្តសាលដីកានេះ ឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវ តាមច្បាប់ ។***

| ***ក្រឡាបញ្ជី*** | ***ចៅក្រមប្រឹក្សា*** | ***ប្រធានក្រុមប្រឹក្សាជំនុំជម្រះ*** |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| លោក [redacted] | លោក [redacted], [redacted] | លោក [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញថ្ងៃទី ១៦ ខែ ០៤ ឆ្នាំ ២០១៥
ក្រឡាបញ្ជី
[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ ភ្នំពេញ

សំណុំរឿង **ព្រហ្មទណ្ឌ**
**លេខ: ៩០១**
ចុះថ្ងៃទី ១៧/៩/២០១២
**សាលដីកា**
**លេខ:** ១២ ក្រ.IV "ច"
ចុះថ្ងៃទី ០៣/៤/២០១៣

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រិត្យលេខ ០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈឆ្នាំ១៩៩៣ បាន បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ០៣មេសា២០១៣ ដោយមានសមាសភាពចូលរួមដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៩០១ ចុះថ្ងៃទី ១៧-៩-២០១២ រវាង:

-ជនជាប់ចោទឈ្មោះ [redacted] បញ្ញា ភេទប្រុស អាយុ ២១ឆ្នាំជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ទីលំនៅមុនចាប់ខ្លួន [redacted] មុខរបរនិស្សិត (នៅលីវ) ។ ឪពុកឈ្មោះ [redacted] "រ ម្តាយឈ្មោះ [redacted] "រ ទោសពីមុនគ្មាន ។ ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៨៣ ត.ព្រ ចុះថ្ងៃទី ០៣/០២/២០១២ ។

-ជនជាប់ចោទឈ្មោះ [redacted] លក្ខិណា ភេទស្រី អាយុ ២១ឆ្នាំជាតិខ្មែរ ។ ទីកន្លែងកំណើតនៅភូមិ [redacted] ទីលំនៅមុនចាប់ខ្លួនផ្ទះ [redacted] មុខរបរនិស្សិត(នៅលីវ)។ឪពុកឈ្មោះ [redacted] "រម្តាយ [redacted] "ស ទោសពីមុនគ្មាន ។ ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ១៨២ត.ព្រ ចុះថ្ងៃទី ០៣/០២/២០១២ ។

***ជាប់ចោទពីបទ:*** **លួច** (ឆក់ខ្សែក) ប្រព្រឹត្តនៅចំណុចចំហៀងខាងកើត ធនាគារកាណាឌីយ៉ា ផ្លូវលេខ ២៨២ ក្រុម៥ ភូមិ ១ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០/០១/២០១២

បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ១៨ឆ្នាំ មុខរបរ ជំនួយការពេទ្យធ្មេញ សៀងឃុន ទីលំនៅផ្ទះលេខ [redacted] ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទ**

-តាមពាក្យបណ្តឹងរបស់ឈ្មោះ [redacted] បានប្តឹងពីឈ្មោះ [redacted] បញ្ញា ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] លក្ខិណា ភេទស្រី អាយុ ២១ឆ្នាំជាតិខ្មែរ**ពីបទ:** ឆក់ខ្សែក ដោយសំអាងហេតុថា: កាលពីថ្ងៃទី ២០ខែមករា ឆ្នាំ២០១៦ វេលាម៉ោង ១៣ $^{H}$៣០នាទី ជនល្មើសបានធ្វើសកម្មភាពជិះម៉ូតូ ១គ្រឿងម៉ាក HONDA C125 សេរី ២០១៦-ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ 1BC 0765 បានធ្វើសកម្មភាពឆក់ខ្សែកបា្ទទីនរបស់ខ្លួន ១ខ្សែទម្ងន់ ១ជីកន្លះបានសម្រេច នៅចំណុចក្បែររបងធានាគារកាណាឌីយ៉ា ចំហៀងខាងកើតផ្លូវ ២៨៤ ក្រុម៥ ភូមិ១ សង្កាត់ អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

-រឿងនេះសាលាលដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តី តាមអំណាចសាលក្រមព្រហ្មទណ្ឌ លេខ ២៨ -ម- ចុះថ្ងៃទី ១៣/៧/២០១៦ ដែលមានខ្លឹមសារដូចតទៅៈ

-ផ្តន្ទាទោស:

ក/ឈ្មោះ [redacted] បញ្ញា ភេទប្រុស អាយុ ២១ឆ្នាំជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយ:ពេល ២ឆ្នាំ(ពីរ) ។

ខ/ឈ្មោះ [redacted] លក្ខិណា ភេទស្រី អាយុ ២១ឆ្នាំជាតិខ្មែរដាក់ពន្ធនាគារកំណត់រយ:ពេល១ឆ្នាំ(មួយ)។

**ពីបទ: លួច** (ឆក់ខ្សែក) ប្រព្រឹត្តនៅចំណុចចំហៀងខាងកើតធនាគារកាណាឌីយ៉ា ដែលស្ថិតនៅផ្លូវលេខ ២៨៤ ក្រុម៥ ភូមិ១ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញកាលពីថ្ងៃទី ២០/០១/២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណ:នៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] បញ្ញា និងឈ្មោះ [redacted] លក្ខិណា កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ។ បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ [redacted] បញ្ញា ប្តឹងឧទ្ធរណ៍និងសាលក្រមលេខ ២៨ -ម- ចុះថ្ងៃទី ១៣/៧/២០១៦ ត្រង់ចំណុចសេចក្តីសម្រេច ទាំងមូល ។

-បានឃើញរបាយការណ៍សន្និដ្ឋានរបស់តំណាងមហាអយ្យការចុះថ្ងៃទី ២៥/១៦/២០១៦ ។

-បានឃើញរបាយការណ៍សង្ខេបអង្គហេតុចុះថ្ងៃទី ០៦/១១/២០១៦ ។

**នាពេលសវនាការ**

*ចៅក្រមអានរបាយការណ៍សង្ខេបអង្គហេតុ*

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] បញ្ញា នាពេលសវនាការបានសារភាពបញ្ជាក់ថា: កាលពីថ្ងៃទី ២០/០១/២០១៦ វេលាម៉ោង ១៣$^{H}$៣០នាទី ខ្ញុំបាទបានជិះម៉ូតូម៉ាក HONDA សេ ១២៥ ពណ៌ខ្មៅ ពាក់

ស្លាកលេខភ្នំពេញ 1BC 0765 ឌុបសង្សាខ្ញុំឈ្មោះ [redacted] លក្ខិណា ពីផ្ទះជួលដើម្បីទៅដើរលេង,មកដល់ជិតធនាគារកាណាឌីយ៉ា ខ្ញុំបាទក៏បានធ្វើសកម្មភាពឆក់ខ្សែកជនរងគ្រោះហើយក៏ហុចខ្សែកនោះឲ្យទៅសង្សារខ្ញុំទុក ហើយជិះម៉ូតូគេចខ្លួនមកផ្សារពាមកពក្នុងសង្កាត់បឹងកក់២ ឲ្យជាងផ្សារខ្សែកនោះ ហើយយកទៅលក់នៅផ្សារសាមគ្គី សង្កាត់ផ្សារដេប៉ូ ៣ បានតម្លៃ ៤៥$ (សែសិបប្រាំដុល្លាអាមេរិក) ដល់ថ្ងៃទី ២៩/០១/២០១២ ខ្ញុំបាទនិងសង្សារក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ពេលខ្ញុំធ្វើសកម្មភាពនោះ សង្សាខ្ញុំមិនបានដឹងអ្វីទេ ពេលឆក់បានហើយទើបសង្សារខ្ញុំដឹង ។

*សំណូមពរ:* សុំឲ្យតុលាការបន្ធូរបន្ថយទោស និង សុំឲ្យតុលាការ មេត្តាលើកលែងការចោទប្រកាន់ដល់សង្សាខ្ញុំឈ្មោះ [redacted] លក្ខិណា ផង ព្រោះខ្ញុំប្រព្រឹត្តតែម្នាក់ឯងទេ ។

**សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ**

-ជនជាប់ចោទឈ្មោះ [redacted] បញ្ញា បានសារភាពថាខ្លួនបានជិះម៉ូតូម៉ាក C125 ឌុបសង្សារឈ្មោះ [redacted] លក្ខិណា ពីផ្ទះជួលដើម្បីដើរលេង ។ លុះមកដល់ជិតធនាគារកាណាឌីយ៉ា ក៏បានធ្វើសកម្មភាពឆក់ខ្សែកពីជនរងគ្រោះបានមួយកំណាត់ឲ្យទៅសង្សារខ្លួនទុកហើយយកទៅលក់នៅផ្សារសាមគ្គីបានតម្លៃ៤៥$។

-ចម្លើយសារភាព និងមានកស្តុតាងគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ។

-សេចក្តីសម្រេច និងសំអាងហេតុនៃសាលក្រមរបស់សាលាដំបូងមានលក្ខណៈត្រឹមត្រូវ គប្បីតម្កល់សាលក្រមនេះទុកជាបានការ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

**សាលាឧទ្ធរណ៍**

**យល់ឃើញថា**

១/ពាក្យបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ [redacted] បញ្ញា ចុះថ្ងៃទី ០៦/៨/២០១២ ប្តឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៨៥ប-ចុះថ្ងៃទី ១៣/៧/២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌសាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន ។

២/នាពេលសវនាការសាលាឧទ្ធរណ៍ ជនជាប់ចោទឈ្មោះ [redacted] បញ្ញា នៅតែសារភាពថាខ្លួនបានជិះម៉ូតូម៉ាក C125 ឌុបសង្សារឈ្មោះ [redacted] លក្ខិណា ពីផ្ទះជួលដើម្បីដើរលេង លុះមកដល់ជិតធនាគារកាណាឌីយ៉ា ខ្លួនបានឆក់ខ្សែកពីនារីម្នាក់នោះបានមួយកំណាត់ហុចឲ្យសង្សារខ្លួនទុក ហើយយកទៅលក់នៅផ្សារសាមគ្គីបានតម្លៃ ៤៥$ ។

ការសារភាពនេះស្របគ្នានឹងចម្លើយសារភាពរបស់ឈ្មោះ [redacted] លក្ខិណា ដែលជាសង្សារថា ពិតជាបានឆក់ខ្សែកពីនារីម្នាក់ជាមួយឈ្មោះ [redacted] បញ្ញា មែន ។